# វិធីសាស្ត្រគ្រប់គ្រង
# ផ្កាចន្ទ
# ក្រោយពេលប្រមូលផល



មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា
Centre d'Etude et de Développement Agricole Cambodgien

វិទ្យាស្ថានអន្តរជាតិដើម្បីស្តារជនបទឡើងវិញ
International Institute of Rural Reconstruction

ឧបត្ថម្ភដោយ មូលនិធិ ម៉ាកណាយ
Funded by McKnight Foundation

## ១) ការប្រមូលផល

ដើម្បីប្រមូលផលផ្កាចន្ទឱ្យបានល្អត្រឹមត្រូវ យើងគួរត្រូវយកចិត្តទុកដាក់លើកត្តាមួយចំនួនដូចខាងក្រោម :

- សង្កេតឃើញទងផ្កាចេញកញ្ចុំអស់ ហើយមានពកស១ច្រើន (ការកាត់របៀបនេះសំរាប់លក់ជាទង)
- អាចកាត់បាននៅពេលគេសង្កេតឃើញកញ្ចុំនៃផ្ការីកប្រមាណ ២០-៣០% (ការកាត់របៀបនេះសំរាប់យកទៅចងជាមួយផ្កាផ្សេងទៀត)
- គួរប្រមូលផលបាននៅពេលព្រឹកចាប់ពីម៉ោង ៨-១១ និងការប្រមូលផលនៅពេលល្ងាចចាប់ពីម៉ោង ៣-៥។ វាជាពេលវេលាមួយល្អសំរាប់ផ្កាចន្ទ ព្រោះផ្កាមានសភាពរឹងមាំល្អ ស្រស់ទឹកសន្សើមដែលអាចធ្វើឱ្យផ្កាមិនងាយរលួយបាន
- ពេលប្រមូលផល យើងត្រូវជ្រើសរើសយកកាំបិតចុងស្រួចមុតល្អ ដោយកាត់ធ្វើយ៉ាងប្រុងប្រយ័ត្នបំផុតដើម្បីកុំឱ្យខូចគល់ផ្កា។ កាត់ជាចំណិតត្រសក់ ហើយទុកទងឱ្យបានវែងល្អ ដើម្បីទុកបានយូរ និងអាចធ្វើការតឹរមបានសមស្របតាមសេចក្តីត្រូវការ។ នៅពេលកាត់ ធ្វើយ៉ាងណោកុំឱ្យប៉ះពាល់ដល់កូនទងតូច១ ផ្សេងទៀត និងធ្វើឱ្យដើមមេមានដំបៅ

- អាចប្រមូលផលនៅពេលមានអាកាសធាតុស្ងួត ប៉ុន្តែ មិនត្រូវឱ្យប៉ះពាល់ផ្ទាល់កំដៅព្រះអាទិត្យទេ
- ជំងឺផ្សេងៗ ជាពិសេសផ្សិតអាចកើតមានឡើងយ៉ាងឆាប់រហ័សនៅពេលដែលយើងប្រមូលផលភ្លាមៗ បន្ទាប់ពីមានភ្លៀងធ្លាក់។




## ២) ការតំរឹម និងការសំអាត

ក្រោយពីប្រមូលផលរួច ដើម្បីឱ្យផ្កាមានសភាពល្អ យើងធ្វើការសំអាត និងតំរឹមដូចតទៅ :

- ត្រូវដឹកជញ្ជូនដាក់ក្នុងម្លប់ត្រជាក់ភ្លាមៗ ជៀសវាងកុំឱ្យវាស្វិតស្រពោនទាន់
- ការតំរឹមធ្វើឡើងជាពីរប្រភេទគឺ : លេខ ១ និងលេខ ២ ដោយលេខ ១ ទុកប្រវែង ៧-៨ តឹក លេខ ២ ទុក ៥ តឹក។ ការតំរឹម យើងយកវាទៅតំរៀបលើដុំឈើ ដើម្បីកាត់វាកុំឱ្យមានបែកទង ដែលជាហេតុនាំឱ្យងាយរលួយស្អុយ
- យើងត្រូវបេះស្លឹកដែលខូចចោល ឬស្លឹកមានស្នាមសត្វបំផ្លាញ ដើម្បីការពារមេរោគឆ្លង
- ការតំរឹម និងការសំអាតនេះធ្វើឡើងនៅក្រោមម្លប់ត្រជាក់ ឬក្រោមផ្ទះ។



## ៣) ការជ្រើសរើស

ផ្កាចន្ទជាប្រភេទផ្កាមេ យើងអាចប្រើវាតែឯក-ឯងក៏បាន ឬជាចំរុះជាមួយផ្កាផ្សេងទៀតក៏បាន។ ដូច្នេះការជ្រើសរើសផ្កាចន្ទ គឺមានបីប្រភេទគឺ:

ផ្កាចន្ទ ដែលចាត់ទុកជាប្រភេទលេខ ១ គឺមាន : ដងដើមចាប់ពី ៧ តឹកឡើងទៅ កញ្ចុំផ្កាធំល្អ ហើយរីកមិនលើសពី ២០% ។ ចំពោះលេខ ២ វិញ មាន ដើមដងចន្លោះពី ៥-៧ តឹក មានកញ្ចុំផ្កាល្អ និងរីកមិន លើសពី ៣០% ក្រៅពីនោះ យើងចាត់ទុកប្រភេទផ្កាលេខ ៣ ដែលអាចយកទៅចង លក់ជាមួយផ្កាផ្សេងទៀត។



## ៤) ការវេចខ្ចប់ និងដឹកជញ្ជូន

ការវេចខ្ចប់ គឺជាការងារចាំបាច់ដែលយើងត្រូវធ្វើ ក្នុងនោះមាន :

- ការចងជាបាច់ៗ (ដែលចងមាន ៥ ដុំ ស្មើ ១០០ ដើម តាមប្រភេទលេខរបស់វា លេខ ១ និងលេខ ២)
- គេអាចចងវាដោយខ្សែកំប្លោក ឬខ្សែចេក
- ក្រោយមក យើងតំរៀបផ្កានោះដាក់ក្នុងអង្រឹង ឬ កញ្ជេ ដើម្បីដឹកជញ្ជូនទៅទីផ្សារ។ ក្នុងការតំរៀប យើងគួរតំរៀបផ្កាបញ្ឈរ ប្រសើរជាងផ្តេក ដោយរក្សាទុកឱ្យមានប្រឡោះខ្យល់ចេញចូលបានល្អផង។ ការវេចខ្ចប់នេះ យើងគួរប្រើស្លឹកចេក ឬស្លឹកឈូកស្រស់ មកទ្រាប់អង្រឹង ឬកញ្ជេដែលមានកំរាស់ក្រាស់ល្មម និងមានហ៊ុំព័ទ្ធសងខាងផង ហើយលើដុំផ្កានិមួយៗ ក៏មានហ៊ុំផងដែរ
- ដាក់ផ្តេកផ្កានៅក្នុងកញ្ជេប្រហែលកំពស់ ២ តឹក
- ការដឹកជញ្ជូន យើងត្រូវថ្នមបំផុត ជៀសវាងការប៉ះ-ទង្គិចខ្លាំងដែលនាំឱ្យខូចកញ្ចុំផ្កា។









## ៥) ការស្តុកទុក

ការស្តុកទុករបស់ផ្កាចន្ទូ ជាការចាំបាច់មួយដោយ យើងយកវាទៅទុកនៅក្នុងបាសាំងទឹក ពាង ប៉ោត ចានដែក ដែលដាក់ផ្កាក្នុងទឹកនោះជំរៅ ២-៤ ធ្នឹង ការពារកុំឱ្យផ្កាស្រពោន។ យើងគួរដាក់វានៅកន្លែងម្លប់ត្រជាក់ មានខ្យល់ចេញចូលបានល្អ។ នៅពេលទុកបានមួយថ្ងៃ ត្រូវប្តូរទឹកចេញ កុំឱ្យស្អុយទឹកងាយរលួយដើម។ នៅពេលប្តូរទឹក យើងត្រូវកាត់គល់វា បើគល់នោះរលួយ ហើយត្រូវចិតជាចំណិតត្រសក់ដដែល ដើម្បីឱ្យវាអាចស្រូបយកទឹកបាន។ ការធ្វើរបៀបនេះ យើងអាចរក្សាទុករយៈពេល ៧ ថ្ងៃ ដោយពុំខូចគុណភាពឡើយ។



**កសិករមានបទពិសោធន៍ និង បានធ្វើការសាកល្បង**

នូ សន ហែន ប៉ាត អួន ថុល និង ឌុក ម៉ៅ